| | |
|---|---|
| លេខកម្ចី/ជំនួយឥតសំណង របស់ ADB និង ឈ្មោះគម្រោង៖ | |
| លេខកិច្ចសន្យា និង ការពណ៌នា៖ | |
| ឈ្មោះអ្នកផ្គត់ផ្គង់/អ្នកម៉ៅការ ៖ | |
| ចំនួនទឹកប្រាក់ក្នុងកិច្ចសន្យា ៖ | |
| រៀបចំដោយ ៖ | |
| កាលបរិច្ឆេទ ៖ | |
| ត្រួតពិនិត្យឡើងវិញ/ឯកភាពដោយ ៖ | |
| កាលបរិច្ឆេទ ៖ | |

**សេចក្តីណែនាំ ៖**

*ការទទួលខុសត្រូវអនុវត្តគម្រោង និងការផ្តល់ជូន ព្រមទាំងការគ្រប់គ្រងកិច្ចសន្យាក្រោមគម្រោងដែលទទួលបានហិរញ្ញប្បទាន ឬ ការគាំទ្រពីធនាគារអភិវឌ្ឍន៍អាស៊ី គឺជាការទទួលខុសត្រូវរបស់អ្នកខ្ចី។ ទីភ្នាក់ងារប្រតិបត្តិ ទីភ្នាក់ងារអនុវត្ត អង្គភាពគ្រប់គ្រងគម្រោង និងអង្គភាពអនុវត្តគម្រោង ទទួលខុសត្រូវរក្សាការជឿទុកចិត្តរបស់ដៃគូដែលពាក់ព័ន្ធ និងធនាគារអភិវឌ្ឍន៍អាស៊ី នៅក្នុងប្រព័ន្ធលទ្ធកម្ម តាមរយៈការធ្វើលទ្ធកម្មក្នុងលក្ខណៈមួយប្រកបដោយគុណនេយ្យភាព មិនលម្អៀង អព្យាក្រឹត្យ និងមានតម្លាភាព។*

*បញ្ជីផ្ទៀងផ្ទាត់នេះ មានគោលបំណង (១) កំណត់ថាតើការធ្វើលទ្ធកម្មទំនិញ និងការងារសំណង់ស៊ីវិលស្ថិតក្រោមការដេញថ្លៃប្រកួតប្រជែងអន្តរជាតិ (ICB) បានអនុវត្តតាមលក្ខខណ្ឌតម្រូវចាំបាច់នៃគោលការណ៍ណែនាំស្តីពីលទ្ធកម្មរបស់ធនាគារអភិវឌ្ឍន៍អាស៊ី រាប់បញ្ចូល សេចក្តីណែនាំអំពីការវាយតម្លៃរបស់ធនាគារអភិវឌ្ឍន៍អាស៊ីផងដែរ និង (២) ដើម្បីធានាថាវិធានការនានាកំពុងត្រូវបានអនុវត្តដើម្បីកាត់បន្ថយឱកាសប្រព្រឹត្តអំពើលួចបន្លំ អំពើពុករលួយ និងការរំលោភបំពានធនធាននៅក្នុងគម្រោងដែលបានទទួលហិរញ្ញប្បទានគាំទ្រ និងគ្រប់គ្រងដោយ/គាំទ្រដោយធនាគារអភិវឌ្ឍន៍អាស៊ី។*

*ប្រសើរបំផុត បញ្ជីផ្ទៀងផ្ទាត់នេះគប្បីត្រូវបានបំពេញសម្រាប់កិច្ចសន្យាដេញថ្លៃប្រកួតប្រជែងអន្តរជាតិនីមួយៗដោយបុគ្គលិកលទ្ធកម្មសំខាន់ៗរបស់គម្រោងនៃទីភ្នាក់ងារប្រតិបត្តិ ទីភ្នាក់ងារអនុវត្ត ឬ អង្គភាពគ្រប់គ្រងគម្រោង។*

| ល.រ | សំនួរ | Y | N | NA | កំណត់សម្គាល់/សម្រាប់ចំណាត់ការ |
|---|---|---|---|---|---|
| **ក.** | **ការរៀបចំឯកសារដេញថ្លៃ និងការអញ្ជើញឱ្យចូលរួម** | | | | |
| 1 | តើការធ្វើលទ្ធកម្ម ICB ត្រូវបានធ្វើឡើងស្របតាមកិច្ចព្រមព្រៀងកម្ចី និងផែនការលទ្ធកម្មដែលបានអនុម័តដែរឬទេ? | | | | |
| | • ប្រសិនបើមិនស្របតាមកិច្ចព្រមព្រៀង និងផែនការទេនោះ តើយើងមានការផ្ដល់ហេតុផល និងការអនុម័តសមស្របពីធនាគារអភិវឌ្ឍន៍អាស៊ី សម្រាប់ការធ្វើលទ្ធកម្ម ICB នេះដែរឬទេ? | | | | សូមបញ្ជាក់អំពីហេតុផល និងអ្នកដែលមានសិទ្ធិផ្ដល់ការអនុម័ត។ |
| | • ប្រសិនបើការធ្វើលទ្ធកម្ម ICB នេះមិនត្រូវបានធ្វើឡើងស្របតាមកិច្ចព្រមព្រៀងកម្ចី និងផែនការលទ្ធកម្មដែលបានអនុម័តទេនោះ តើផែនការលទ្ធកម្មត្រូវបានធ្វើបច្ចុប្បន្នភាពសមស្របដែរឬទេ? | | | | សូមបញ្ជាក់អំពីកាលបរិច្ឆេទដែលផែនការលទ្ធកម្មត្រូវបានធ្វើបច្ចុប្បន្នភាព។ |
| 2 | តើលិខិតអញ្ជើញឱ្យចូលរួមការដេញថ្លៃ (IFB) បានទទួលការអនុម័តពីធនាគារអភិវឌ្ឍន៍អាស៊ីដែរឬទេ? | | | | សូមបញ្ជាក់អំពីកាលបរិច្ឆេទដែលធនាគារអភិវឌ្ឍន៍អាស៊ីបានអនុម័តទៅលើលិខិតអញ្ជើញឱ្យចូលរួមការដេញថ្លៃ។ |
| | • តើកាលបរិច្ឆេទឱសានវាទ និងទីកន្លែងទទួលឯកសារដេញថ្លៃ មានបញ្ជាក់នៅក្នុងលិខិតអញ្ជើញឱ្យចូលរួមការដេញថ្លៃដែរឬទេ? | | | | សូមបញ្ជាក់អំពីកាលបរិច្ឆេទឱសានវាទ និងទីកន្លែងទទួលឯកសារដេញថ្លៃ នៅក្នុងលិខិតអញ្ជើញឱ្យចូលរួមការដេញថ្លៃ។ |
| | • តើយើងបានផ្សព្វផ្សាយអំពីលទ្ធកម្ម ICB នេះស្របតាមប្រព័ន្ធផ្សព្វផ្សាយដែលគេបានកំណត់ដែរឬទេ (ឧ. សារព័ត៌មានដែលផ្សព្វផ្សាយទូទាំងប្រទេស ឬគេហទំព័រជាភាសាអង់គ្លេសដែលគេស្គាល់ទូទៅជាអន្តរជាតិ និងអាចចូលមើលបានដោយសេរី? | | | | សូមបញ្ជាក់អំពីប្រព័ន្ធផ្សព្វផ្សាយដែលបានប្រើប្រាស់ដើម្បីផ្សព្វផ្សាយអំពីលទ្ធកម្ម ICB នេះ។ ប្រសិនបើផ្សព្វផ្សាយនៅក្នុងគេហទំព័រ សូមបញ្ជាក់អំពីអសយដ្ឋានរបស់គេហទំព័រនោះ។ |
| | • តើយើងបានរក្សាទុកលិខិតផ្សព្វផ្សាយក្នុងទម្រង់ជាឯកសារបោះពុម្ព ដែរឬទេ? | | | | |

| | | | | | |
|---|---|---|---|---|---|
| 3 | តើឯកសារដេញថ្លៃស្តង់ដារដែលបានចេញជូនអ្នកដេញថ្លៃ ត្រូវបានត្រួតពិនិត្យឡើងវិញ និងអនុម័តដោយធនាគារអភិវឌ្ឍន៍អាស៊ី ដែរឬទេ? | | | | សូមបញ្ជាក់អំពីកាលបរិច្ឆេទដែលធនាគារអភិវឌ្ឍន៍អាស៊ីបានផ្តល់ការអនុម័ត។ |
| | • តើឯកសារដេញថ្លៃស្តង់ដារដែលបានចេញជូនអ្នកដេញ ត្រូវបានត្រួតពិនិត្យឡើងវិញ ដើម្បីធានាថាឯកសារទាំងនោះ គឺដូចគ្នាទៅនឹងឯកសារដែលអនុម័តដោយធនាគារអភិវឌ្ឍន៍អាស៊ី ដែរឬទេ? | | | | |
| 4 | តើមានការធ្វើវិសោធនកម្មណាមួយទៅលើឯកសារដេញថ្លៃស្តង់ដារក្រោយពេលដែលឯកសារទាំងនេះ ត្រូវបានផ្តល់ជូនទៅឱ្យអ្នកដេញថ្លៃ ដែរឬទេ? | | | | សូមបញ្ជាក់អំពីវិសោធនកម្មដែលត្រូវបានធ្វើឡើង។ |
| | • ប្រសិនបើមានការធ្វើវិសោធនកម្ម តើការផ្លាស់ប្តូរទាំងនេះ បានទទួលការអនុម័តពីធនាគារអភិវឌ្ឍន៍អាស៊ីដែរឬទេ? | | | | |
| 5 | តើយើងបានធ្វើការកត់ត្រាព័ត៌មានរបស់អ្នកដេញថ្លៃដែលបានទិញឯកសារដេញថ្លៃ ICB ដែរឬទេ? | | | | សូមបញ្ជាក់អំពី (១) តម្លៃឯកសារដេញថ្លៃ និង (២) ចំនួនអ្នកដេញថ្លៃដែលបានទិញឯកសារដេញថ្លៃ។ |
| **ខ.** | **ឯកសារដេញថ្លៃដែលបានទទួល** | | | | |
| 6 | តើមានសន្និសីទ/កិច្ចប្រជុំមុនពេលដេញថ្លៃ និងការចុះទស្សនកិច្ចផ្ទាល់ដល់ទីតាំងគម្រោង ដែលត្រូវបានរៀបចំសម្រាប់អ្នកដេញថ្លៃ ដែរឬទេ? | | | | ប្រសិនបើពុំមានទេនោះ សូមបញ្ជាក់អំពីមូលហេតុ។ |
| 7 | តើមានសំណើសុំការបញ្ជាក់ ព័ត៌មានបន្ថែម និង/ឬ ការកែតម្រូវទៅលើកំហុសនានា នៅក្នុងឯកសារដេញថ្លៃស្តង់ដារ ពីភាគីអ្នកដេញថ្លៃដែរឬទេ? | | | | |
| | • តើសំណើពីអ្នកដេញថ្លៃទាំងនេះ ត្រូវបានធ្វើឡើងជាលាយលក្ខណ៍អក្សរដែរឬទេ? | | | | |
| | • តើការឆ្លើយតបរួមគ្នារបស់យើងចំពោះសំណើសុំការបញ្ជាក់ ព័ត៌មានបន្ថែម | | | | |

| | | | | | |
|---|---|---|---|---|---|
| | និង/ឬ ការកែតម្រូវកំហុសដែលបានទទួលពីភាគីអ្នកដេញថ្លៃ ត្រូវបានធ្វើឡើងជាលាយលក្ខណ៍អក្សរ ដែរឬទេ? | | | | |
| | • តើយើងមានភស្តុតាងបញ្ជាក់ថា ការឆ្លើយតបរួមគ្នារបស់យើង ឬ ការផ្លាស់ប្តូរទៅលើឯកសារដេញថ្លៃ ត្រូវបានបញ្ជូន និងបានទទួលដោយអ្នកដេញថ្លៃគ្រប់រូបដែលបានដេញឯកសារដេញថ្លៃ ដែរឬទេ? | | | | |
| 8 | ប្រសិនបើមានការពន្យារកាលបរិច្ឆេទឱសានវាទ សម្រាប់ដាក់ជូនឯកសារដេញថ្លៃ តើការពន្យារនេះ បានទទួលការអនុម័តពីធនាគារអភិវឌ្ឍន៍អាស៊ី ដែរឬទេ? | | | | សូមបញ្ជាក់ថាតើកាលបរិច្ឆេទឱសានវាទសម្រាប់ដាក់ជូនឯកសារដេញថ្លៃត្រូវបានពន្យារចំនួនប៉ុន្មានដង និងដោយសារមូលហេតុអ្វី។ |
| | • តើយើងបានប្រាស្រ័យទាក់ទងជាលាយលក្ខណ៍អក្សរអំពីកាលបរិច្ឆេទឱសានវាទថ្មីជាមួយអ្នកដេញថ្លៃ ដែលបានទិញឯកសារដេញថ្លៃដែរឬទេ? | | | | ប្រសិនបើពុំមានការប្រាស្រ័យទាក់ទងលាយលក្ខណ៍អក្សរទេនោះ សូមបញ្ជាក់ថាតើព័ត៌មាននេះត្រូវបានផ្តល់ជូនទៅឱ្យអ្នកដែលទំនងនឹងក្លាយជាដេញថ្លៃដោយរបៀបណា។ |
| 9 | តើយើងមានបញ្ជី/សៀវភៅកត់ត្រា ដើម្បីកត់ត្រាអំពីឯកសារដេញថ្លៃដែលបានទទួល កាលបរិច្ឆេទ និងពេលវេលាដែលបានទទួល និងហត្ថលេខារបស់អ្នកដែលបានដាក់ជូនឯកសារដេញថ្លៃ (ក្នុងករណីដែលអាចធ្វើទៅបាន) ដែរឬទេ? | | | | សូមបញ្ជាក់ថាតើគេបានទទួលឯកសារដេញថ្លៃចំនួនប៉ុន្មាន សម្រាប់លទ្ធកម្ម ICB នេះ។ |
| | • ប្រសិនបើយើងទទួលបានឯកសារដេញថ្លៃតិចជាង៣ សម្រាប់លទ្ធកម្ម ICB នេះ តើយើងធ្វើការដេញថ្លៃឡើងវិញដែរឬទេ? | | | | ប្រសិនបើការដេញថ្លៃឡើងវិញ មិនត្រូវបានអនុវត្ត សូមបញ្ជាក់អំពីមូលហេតុ។ |
| 10 | តើយើងបានបញ្ជូនឯកសារដេញថ្លៃដែលបានទទួល ត្រឡប់ទៅឱ្យអ្នកដេញថ្លៃទាំងមិនបើកមើលវិញដែរឬទេ ក្រោយពេលហួសកាលបរិច្ឆេទឱសានវាទសម្រាប់ដាក់ជូន? | | | | សូមបញ្ជាក់ថាតើគេទទួលបានឯកសារដេញថ្លៃដែលដាក់មកយឺតចំនួនប៉ុន្មាន។ |

| | | | | | |
|---|---|---|---|---|---|
| **គ.** | **ការបើកឯកសារដេញថ្លៃ** | | | | |
| 11 | តើពេលវេលា និងទីកន្លែងសម្រាប់បើកឯកសារដេញថ្លៃ ដូចគ្នាទៅនឹងកាលបរិច្ឆេទឱសានវាទ ឬ ភ្លាមៗក្រោយមកទៀត ដូចមានប្រកាសនៅក្នុងលិខិតអញ្ជើញឱ្យចូលរួមការដេញថ្លៃ? | | | | ប្រសិនបើមិនដូច្នោះទេ សូមបញ្ជាក់អំពីមូលហេតុ។<br><br>សូមបញ្ជាក់អំពីកាលបរិច្ឆេទ ពេលវេលា និងទីកន្លែងបើកឯកសារដេញថ្លៃ។ |
| 12 | តើយើងបានរៀបចំកំណត់ត្រានៃការបើកឯកសារដេញថ្លៃ ដែរឬទេ? | | | | |
| | • តើកំណត់ត្រានៃការបើកឯកសារដេញថ្លៃយ៉ាងហោចណាស់ រួមមានព័ត៌មានខាងក្រោមដែរឬទេ ៖ (១) ឈ្មោះ និងអសយដ្ឋានអ្នកដេញថ្លៃ (២) ចំនួនប្រាក់ធានាការដេញថ្លៃ (៣) ចំនួនទឹកប្រាក់ដេញថ្លៃ (៤) ការបញ្ចុះតម្លៃដែលបានផ្តល់ជូនប្រសិនបើមាន (៥) ការដេញថ្លៃដោយឡែក ប្រសិនបើអនុញ្ញាត និង (៦) ហត្ថលេខារបស់តំណាងអ្នកដេញថ្លៃ? | | | | សូមបញ្ជាក់ថាតើព័ត៌មានណាខ្លះដែលមិនត្រូវបានកត់ត្រា។ |
| | • តើកំណត់ហេតុបើកឯកសារដេញថ្លៃត្រូវបានចុះហត្ថលេខាដោយសមាជិកគណៈកម្មាធិការបើកឯកសារដេញថ្លៃគ្រប់រូបដែរឬទេ (ឬ បុគ្គលដែលទទួលខុសត្រូវបើកឯកសារដេញថ្លៃ)? | | | | សូមបញ្ជាក់ថាតើសមាជិកគណៈកម្មាធិការបើកឯកសារដេញថ្លៃណាខ្លះ ដែលមិនបានចុះហត្ថលេខាទៅលើកំណត់ហេតុបើកឯកសារដេញថ្លៃ។ |
| | • តើមានបញ្ជីវត្តមានបើកឯកសារដេញថ្លៃសម្រាប់គាំទ្រដល់កំណត់ហេតុបើកឯកសារដេញថ្លៃ ដែលមានការចុះហត្ថលេខាសមស្រប ដោយតំណាងអ្នកដេញថ្លៃនីមួយៗដែលបានចូលរួមបើកឯកសារដេញថ្លៃ ដែរឬទេ? | | | | សូមបញ្ជាក់អំពីតំណាងអ្នកដេញថ្លៃដែលបានចូលរួមនៅក្នុងការបើកឯកសារដេញថ្លៃ ប៉ុន្តែមិនបានចុះហត្ថលេខាទៅលើបញ្ជីវត្តមាន។ |
| | • តើកំណត់ហេតុបើកឯកសារដេញថ្លៃមួយច្បាប់ ត្រូវបានបញ្ជូនទៅឱ្យធនាគារអភិវឌ្ឍន៍អាស៊ី និងអ្នកដេញថ្លៃគ្រប់រូបដែលឯកសារដេញថ្លៃរបស់ពួកគេត្រូវបានបើក ដែរឬទេ? | | | | សូមបញ្ជាក់អំពីកាលបរិច្ឆេទដែលកំណត់ហេតុបើកឯកសារដេញថ្លៃមួយច្បាប់ត្រូវបានផ្ញើទៅឱ្យធនាគារអភិវឌ្ឍន៍អាស៊ី និងអ្នកដេញថ្លៃ។ |

| ឃ. | ការកំណត់អំពីការឆ្លើយតបគួរឱ្យកត់សម្គាល់ចំពោះឯកសារដេញថ្លៃ | | | | |
|---|---|---|---|---|---|
| 13 | តើយើងមានកំណត់ហេតុអំពីការបង្កើតគណៈកម្មាធិការវាយតម្លៃការផ្តល់កិច្ចសន្យាសម្រាប់ ICB នេះ ដែរឬទេ? | | | | សូមបញ្ជាក់អំពីកាលបរិច្ឆេទបង្កើតគណៈកម្មាធិការវាយតម្លៃការផ្តល់កិច្ចសន្យា និងរាយនាមអំពីមាសភាពគណៈកម្មាធិការនេះ។ |
| | តើយើងបានទទួលជំនួយពីទីប្រឹក្សាត្រួតពិនិត្យការងារវាយតម្លៃការដេញថ្លៃ ដែរឬទេ? | | | | សូមបញ្ជាក់អំពីវិសាលភាពនៃជំនួយដែលផ្តល់ដោយទីប្រឹក្សាត្រួតពិនិត្យនៅក្នុងការវាយតម្លៃការដេញថ្លៃ។ |
| 14 | ផ្អែកលើការត្រួតពិនិត្យឡើងវិញរបស់ខ្ញុំទៅលើតារាងទាំងស្រុងនៃឯកសារដេញថ្លៃ និងការដាក់ជូនឯកសារដេញថ្លៃ ៖<br>• តើកំហុសលេខគណិតវិទ្យា ត្រូវបានកែតម្រូវ ដែរឬទេ ប្រសិនបើមាន? | | | | សូមបញ្ជាក់អំពីឯកសារដេញថ្លៃដែលមានកំហុសលេខគណិតវិទ្យា ដែលមិនត្រូវបានកែតម្រូវ។ សូមបញ្ជាក់អំពីតម្លៃដែលត្រូវបានកែតម្រូវ។ |
| | • តើប្រាក់ធានាការដេញថ្លៃរបស់អ្នកដេញថ្លៃ ស្របទៅនឹងលក្ខខណ្ឌតម្រូវប្រាក់ធានាការដេញថ្លៃដែលបានកំណត់ដែរទេ? | | | | សូមបញ្ជាក់អំពីអ្នកដេញថ្លៃដែលប្រាក់ធានាការដេញថ្លៃរបស់ពួកគេ ពុំមានលក្ខខណ្ឌស្របទៅនឹងលក្ខខណ្ឌតម្រូវដែលបានកំណត់។ |
| | • តើអ្នកដេញថ្លៃដែលពុំមានលក្ខខណ្ឌស្របទៅនឹងលក្ខខណ្ឌតម្រូវដែលបានកំណត់ចំពោះប្រាក់ធានាការដេញថ្លៃត្រូវបានដកចេញ ដែរឬទេ? | | | | ប្រសិនបើអ្នកដេញថ្លៃដែលពុំមានលក្ខខណ្ឌស្របទៅនឹងលក្ខខណ្ឌតម្រូវដែលបានកំណត់ចំពោះប្រាក់ធានាការដេញថ្លៃ មិនត្រូវបានដកចេញទេនោះ សូមបញ្ជាក់អំពីមូលហេតុ។ |
| | • តើយើងបានសុំការបញ្ជាក់/ការអនុម័តពីធនាគារអភិវឌ្ឍន៍អាស៊ី ថាមិនដកចេញអ្នកដេញថ្លៃទាំងឡាយណាដែលប្រាក់ធានាការដេញថ្លៃរបស់ពួកគេ មិនស្របទៅនឹងលក្ខខណ្ឌតម្រូវដែលបានកំណត់ដែរឬទេ? | | | | សូមបញ្ជាក់អំពីការឆ្លើយតប និងកាលបរិច្ឆេទរបស់ធនាគារអភិវឌ្ឍន៍អាស៊ីដែលបានផ្តល់ការបញ្ជាក់/ការអនុម័តយ៉ាងដូច្នេះ។ |
| | • តើអ្នកដេញថ្លៃមានលក្ខខណ្ឌស្របទៅនឹងលក្ខណៈវិនិច្ឆ័យដែលបានកំណត់នៅក្នុងឯកសារដេញថ្លៃស្តង់ដារ ដែរឬទេ? | | | | សូមបញ្ជាក់អំពីអ្នកដេញថ្លៃដែលពុំមានលក្ខខណ្ឌស្របទៅនឹងលក្ខណៈវិនិច្ឆ័យ ប៉ុន្តែត្រូវបានចាត់ទុកថាមានភាពសមស្រប។ សូមបញ្ជាក់អំពីមូលហេតុ។ |
| | • តើមានការបញ្ជាក់លាយលក្ខណ៍អក្សរអំពីការប្រគល់សិទ្ធិឱ្យចុះហត្ថលេខា | | | | សូមបញ្ជាក់អំពីអ្នកដេញថ្លៃដែលពុំមានការបញ្ជាក់លាយលក្ខណ៍អក្សរអំពីការ |

| | | | | | |
|---|---|---|---|---|---|
| | ជំនួសឱ្យអ្នកដេញថ្លៃនីមួយៗ ដែរឬទេ? | | | | ប្រគល់សិទ្ធិឱ្យចុះហត្ថលេខា ជំនួសឱ្យអ្នកដេញថ្លៃ ប៉ុន្តែត្រូវបានចាត់ទុកថាមានភាពសមស្រប។ សូមបញ្ជាក់អំពីមូលហេតុ។ |
| | • តើទម្រង់ដេញថ្លៃ និងកាលវិភាគតម្លៃច្បាប់ដើម និងច្បាប់ចម្លង ត្រូវបានចុះហត្ថលេខាដោយបុគ្គលដែលត្រូវបានប្រគល់សិទ្ធិឱ្យចុះហត្ថលេខាជំនួសឱ្យអ្នកដេញថ្លៃ ដែរឬទេ? | | | | សូមបញ្ជាក់ថាតើឯកសាដេញថ្លៃណាខ្លះដែលទម្រង់ដេញថ្លៃ និងកាលវិភាគតម្លៃនៃឯកសារដេញថ្លៃនោះ មិនត្រូវបានចុះហត្ថលេខា ប៉ុន្តែត្រូវបានចាត់ទុកថាមានភាពសមស្រប។ សូមបញ្ជាក់អំពីមូលហេតុ។ |
| | • តើឯកសារដេញថ្លៃគ្រប់ទំព័រ ត្រូវបានចុះហត្ថលេខា ឬ គ្រីស ដោយអ្នកតំណាងរបស់អ្នកដេញថ្លៃ ដែលត្រូវបានប្រគល់សិទ្ធិជូន ដែរឬទេ? | | | | សូមបញ្ជាក់អំពីឯកសារដេញថ្លៃ ដែលពុំមានការចុះហត្ថលេខា ឬ គ្រីស ទៅលើគ្រប់ទំព័រដោយអ្នកតំណាងរបស់អ្នកដេញថ្លៃដែលត្រូវបានប្រគល់សិទ្ធិជូន។ |
| | • ក្នុងករណីមានការកែប្រែ ដូចជា ការសរសេរបញ្ចៀតបន្ថែម ការកោសលុប ឬ ការសរសេរត្រួតគ្នា នៅក្នុងឯកសារដេញថ្លៃដែលបានដាក់ជូន តើការកែប្រែទាំងនេះ ត្រូវបានចុះហត្ថលេខា ឬ គ្រីស ដោយអ្នកតំណាងដែលត្រូវបានប្រគល់សិទ្ធិជូន ដែរឬទេ? | | | | សូមបញ្ជាក់អំពីឯកសារដេញថ្លៃដែលមានការកែប្រែ ដែលមិនត្រូវបានចុះហត្ថលេខា/គ្រីស ដោយអ្នកតំណាងដែលត្រូវបានប្រគល់សិទ្ធិជូន។ |
| 15 | ផ្អែកលើការត្រួតពិនិត្យឡើងវិញរបស់ខ្ញុំទៅលើតារាងដែលមានការឆ្លើយតបសមស្របគួរឱ្យកត់សម្គាល់ និងការដាក់ជូននូវឯកសារដេញថ្លៃ ៖<br><br>• តើរាល់ឯកសារដេញថ្លៃទាំងអស់ ត្រូវបានត្រួតពិនិត្យមើលទៅលើការឆ្លើយតបសមស្របគួរឱ្យកត់សម្គាល់ ចំពោះលក្ខខណ្ឌផ្នែកពាណិជ្ជកម្ម និងលក្ខខណ្ឌតម្រូវបច្ចេកទេស ដែរឬទេ? | | | | សូមបញ្ជាក់អំពីឯកសារដេញថ្លៃដែលមិនត្រូវបានត្រួតពិនិត្យ ដើម្បីស្វែងរកការឆ្លើយតបសមស្របគួរឱ្យកត់សម្គាល់។ សូមបញ្ជាក់អំពីមូលហេតុ។ |
| | • តើមានអ្នកដេញថ្លៃដែលពុំមានលទ្ធភាពផ្គត់ផ្គង់ទៅតាមកាលវិភាគសំខាន់ៗដែលបានកំណត់ ឬ លក្ខខណ្ឌតម្រូវកាលវិភាគការងារ ប៉ុន្តែត្រូវបានចាត់ទុកថាមាន | | | | សូមរាយនាមអ្នកដេញថ្លៃដែលពុំមានលក្ខខណ្ឌស្របតាមកាលវិភាគផ្គត់ផ្គង់ ឬ លក្ខខណ្ឌតម្រូវកាលវិភាគការងារដែលបានកំណត់ ប៉ុន្តែត្រូវបានចាត់ទុកថា |

| | | | | |
|---|---|---|---|---|
| ភាពសមស្រប ដែរឬទេ? | | | | មានភាពសមស្រប។ សូមបញ្ជាក់អំពីមូលហេតុ។ |
| • **សម្រាប់ទំនិញ** តើមានអ្នកផលិត ឬ អ្នកផ្គត់ផ្គង់ ឬ ទាំងផលិត និងអ្នកផ្គត់ផ្គង់ ដែលពុំមានលក្ខខណ្ឌស្របតាមបទពិសោធន៍អប្បបរមា ដូចមានកំណត់ចែងនៅក្នុងឯកសារដេញថ្លៃ ប៉ុន្តែត្រូវបានចាត់ទុកថាមានភាពសមស្រប ដែរឬទេ? | | | | សូមរាយនាមអ្នកដេញថ្លៃដែលអ្នកផលិត/អ្នកផ្គត់ផ្គង់ ពុំមានលក្ខខណ្ឌស្របតាមបទពិសោធន៍អប្បបរមា ប៉ុន្តែត្រូវបានចាត់ទុកថាមានភាពសមស្រប។ សូមបញ្ជាក់អំពីមូលហេតុ។ |
| • តើមានការដេញថ្លៃដោយមានកំណត់លក្ខខណ្ឌដែលត្រូវបានទទួលយក ដែរឬទេ (ឧ. ការទទួលយកកិច្ចសន្យា លុះត្រាណាតែរដ្ឋាភិបាលអនុម័តទៅលើការនាំចេញ ការលក់ជាមុន ឬ ការមានសម្ភារៈវត្ថុធាតុដើមសំខាន់ៗនៅក្នុងទីផ្សារ ឬ ឯកសារដេញថ្លៃដែលបានដាក់ជូន ជាមួយនឹងលក្ខខណ្ឌកំណើនតម្លៃ នៅពេលដែលបញ្ជាក់អំពីតម្លៃកំណត់មួយ)? | | | | សូមរាយនាមអ្នកដេញថ្លៃដែលឯកសារដេញថ្លៃមានកំណត់លក្ខខណ្ឌ ហើយត្រូវបានទទួលយក។ សូមបញ្ជាក់អំពីមូលហេតុនៃការទទួលយក។ |
| • តើមានអ្នកដេញថ្លៃដែលមិនព្រមទទួលយករូបមន្តកែសម្រួលតម្លៃ ដូចមានបញ្ជាក់នៅក្នុងឯកសារដេញថ្លៃស្តង់ដារ ប៉ុន្តែត្រូវបានចាត់ទុកថាមានភាពសមស្រប ដែរឬទេ? | | | | សូមរាយនាមអ្នកដេញថ្លៃដែលមិនទទួលយករូបមន្តកែសម្រួលតម្លៃ ដូចមានបញ្ជាក់នៅក្នុងឯកសារដេញថ្លៃស្តង់ដារ ប៉ុន្តែត្រូវបានចាត់ទុកថាមានភាពសមស្រប។ សូមបញ្ជាក់អំពីមូលហេតុនៃការប្រកាសថាអ្នកដេញថ្លៃទាំងនោះ មានភាពសមស្រប។ |
| • តើមានឯកសារគាំទ្រចម្បងៗដែលឯកសារដេញថ្លៃស្តង់ដារ តម្រូវឱ្យដាក់ជូនដើម្បីកំណត់អំពីភាពសមស្របគួរឱ្យកត់សម្គាល់នៃឯកសារដេញថ្លៃ ដែរឬទេ? | | | | សូមរាយនាមឯកសារគាំទ្រចម្បងៗទាំងនេះដែលតម្រូវឱ្យអ្នកដេញថ្លៃដាក់ជូន។ |
| ○ តើមានអ្នកដេញថ្លៃដែលមិនបានដាក់ជូននូវរាល់ឯកសារចម្បងៗ ដែលចាំបាច់ត្រូវដាក់ជូន ដើម្បីកំណត់អំពីភាពសមស្របគួរឱ្យ | | | | សូមរាយនាមអ្នកដេញថ្លៃទាំងនេះ។ សូមបញ្ជាក់អំពីមូលហេតុនៃការប្រកាសថាពួកគេមានភាពសមស្រប។ |

| | | | | | |
|---|---|---|---|---|---|
| | កត់សម្គាល់នៃឯកសារដេញថ្លៃ ប៉ុន្តែត្រូវបានចាត់ទុកថាមានភាពសមស្រប ដែរឬទេ? | | | | |
| | • តើមានអ្នកដេញថ្លៃដែលមិនបានធ្វើការដេញថ្លៃសម្រាប់ទំហំការងារ ដែលគេត្រូវការ ប៉ុន្តែត្រូវបានចាត់ទុកថាមានភាពសមស្រប ដែរឬទេ? | | | | សូមបញ្ជាក់អំពីអ្នកដេញថ្លៃទាំងនោះ ដោយរាប់បញ្ចូលទំហំការងារដែលពួកគេខកខានក្នុងការដេញថ្លៃ និងត្រូវបានចាត់ទុកថាមានភាពសមស្រប។ សូមបញ្ជាក់អំពីមូលហេតុដែលចាត់ទុកថាពួកគេមានភាពសមស្រប។ |
| | • តើមានអ្នកដេញថ្លៃដែលមិនបានផ្តល់សម្រង់តម្លៃសម្រាប់ខ្ទង់ចម្បងៗ (ប្រមាណ១០% ឬ ច្រើនជាងនេះនៃតម្លៃដេញថ្លៃសរុប ឬ ប្រសិនបើលុបចោលធ្វើឱ្យឯកសារដេញថ្លៃមានលក្ខណៈមិនគ្រប់ជ្រុងជ្រោយគួរឱ្យកត់សម្គាល់) នៅក្នុងកញ្ចប់ ប៉ុន្តែត្រូវបានចាត់ទុកថាមានភាពសមស្រប ដែរឬទេ? | | | | សូមបញ្ជាក់អំពីអ្នកដេញថ្លៃទាំងនេះ ខ្ទង់ចម្បងៗដែលត្រូវបានលុបចោល និងមូលហេតុដែលចាត់ទុកថាពួកគេមានភាពសមស្រប។ |
| | • តើមានអ្នកដេញថ្លៃដែលពុំមានលក្ខណៈស្របតាមលក្ខខណ្ឌតម្រូវបច្ចេកទេសចម្បងៗ ដូចមានបញ្ជាក់នៅក្នុងឯកសារដេញថ្លៃស្តង់ដារ *(ឧ. ការផ្តល់ប្រភេទដែលមានលក្ខណៈខុសគ្នាទាំងស្រុងបើធៀបទៅនឹងប្រភេទដែលបានបញ្ជាក់ សមត្ថភាពរបស់រោងចក្រ មិនទាន់ឈានដល់កម្រិតអប្បបរមាដែលបានបញ្ជាក់ ឧបករណ៍សម្ភារៈមិនអាចបំពេញមុខងារមូលដ្ឋានទៅតាមការចង់បាន។ល។)* ប៉ុន្តែត្រូវបានចាត់ទុកថាមានភាពសមស្រប ដែរឬទេ? | | | | សូមរាយនាមអ្នកដេញថ្លៃទាំងនេះ លក្ខខណ្ឌតម្រូវបច្ចេកទេសចម្បងៗ ដែលមិនស្របទៅតាមការកំណត់ និងមូលហេតុដែលចាត់ទុកថាពួកគេមានភាពសមស្រប។ |
| | • តើមានអ្នកដេញថ្លៃដែលមិនបានផ្តល់របាយការណ៍ធ្វើតេស្តប្រភេទឧបករណ៍សម្ភារៈសំខាន់ៗ ដូចមានបញ្ជាក់នៅក្នុងឯកសារដេញថ្លៃស្តង់ដារ ប៉ុន្តែត្រូវបានចាត់ទុកថាមានភាពសមស្រប ដែរឬទេ? | | | | សូមរាយនាមអ្នកដេញថ្លៃទាំងនេះ និងបញ្ជាក់អំពីមូលហេតុដែលចាត់ទុកថាពួកគេមានភាពសមស្រប។ |

| | | | | | |
|---|---|---|---|---|---|
| **ង.** | **ការវាយតម្លៃឯកសារដេញថ្លៃលម្អិត** | | | | |
| 16 | តើការវាយតម្លៃលម្អិត រាប់បញ្ចូលឯកសារដេញថ្លៃសមស្របគួរឱ្យកត់សម្គាល់ ដែលមានឱកាសសមរម្យ ក្នុងការក្លាយជាឯកសារដេញថ្លៃដែលត្រូវបានវាយតម្លៃថាមានតម្លៃទាបបំផុត ដែរឬទេ? | | | | សូមរាយនាមឯកសារដេញថ្លៃសមស្របគួរឱ្យកត់សម្គាល់ ដែលមិនត្រូវបានបញ្ចូលទៅក្នុងការវាយតម្លៃលម្អិត។ សូមបញ្ជាក់អំពីមូលហេតុដែលមិនបានបញ្ចូល។ |
| 17 | ផ្អែកលើការត្រួតពិនិត្យឡើងវិញរបស់ខ្ញុំទៅលើតារាងវាយតម្លៃលម្អិត និងការដាក់ជូនឯកសារដេញថ្លៃ**ការងារសំណង់ស៊ីវិល**របស់អ្នកដេញថ្លៃ ៖<br><br>• តើការវាយតម្លៃលម្អិត បានបញ្ចូល ៖<br>○ ការវិភាគអត្រាតម្លៃឯកតារបស់រាល់អ្នកដេញថ្លៃសមស្របទាំងអស់ និងការប៉ាន់ប្រមាណ ដែរឬទេ? | | | | ប្រសិនបើពុំមានការវិភាគទៅលើអត្រាតម្លៃឯកតា និងការប៉ាន់ប្រមាណទេនោះ សូមបញ្ជាក់អំពីមូលហេតុ។ |
| | ○ ការវិភាគផែនការ និងកាលវិភាគ (កាលវិភាគសាងសង់ និងគៀងគរវិធីសាស្ត្រ និងអភិក្រមនៃការសាងសង់ កាលវិភាគធនធានមនុស្ស និងឧបករណ៍ , ផែនការសម្រាប់ការរៀបចំការដ្ឋានរបស់អ្នកម៉ៅការ និងការគ្រប់គ្រងកិច្ចសន្យា។ល។) ដែរឬទេ? | | | | សូមរាយនាមអ្នកដេញថ្លៃដែលផែនការ និងកាលវិភាគរបស់ពួកគេ មិនត្រូវបានយកមកវិភាគ។ សូមបញ្ជាក់អំពីមូលហេតុ។ |
| | ○ ការវិភាគទៅលើសំណើឧបករណ៍សម្ភារៈ និង បុគ្គលិក។ | | | | សូមរាយនាមអ្នកដេញថ្លៃដែលសំណើឧបករណ៍សម្ភារៈ និងបុគ្គលិករបស់ពួកគេមិនត្រូវបានយកមកវិភាគ។ សូមបញ្ជាក់អំពីមូលហេតុ។ |
| | ○ តើមានឈ្មោះបុគ្គលិកអ្នកផ្គត់ផ្គង់/អ្នកម៉ៅការ និងឧបករណ៍សម្ភារៈដូចគ្នាទាំងស្រុងដែលបានទទួលសម្រាប់លទ្ធកម្ម ICB នេះ ដែរឬទេ? | | | | សូមរាយនាមឈ្មោះបុគ្គលិកអ្នកផ្គត់ផ្គង់/អ្នកម៉ៅការ និងឧបករណ៍សម្ភារៈដែលមានលក្ខណៈដូចគ្នាទាំងស្រុង (អាចជាការឃុបឃិតគ្នាក្នុងចំណោមអ្នកដេញថ្លៃ)។ |
| 18 | ផ្អែកលើការវិភាគទៅលើតម្លៃឯកតា និងការប៉ាន់ប្រមាណនៅក្នុងចំណុចទី១៧ ខាងលើ ៖ | | | | |

| | | | | | |
|---|---|---|---|---|---|
| | • តើមានតម្លៃឯកតាជាច្រើនរបស់អ្នកដេញថ្លៃមួយក្រុម ដែលដូចគ្នាទាំងស្រុង ឬ ត្រូវបានកំណត់ក្លែងក្លាយ ដែរឬទេ? | | | | សូមបញ្ជាក់អំពីអ្នកដេញថ្លៃដែលមានតម្លៃឯកតាជាច្រើន ដែលដូចគ្នាទាំងស្រុង ឬ ត្រូវបានកំណត់ក្លែងក្លាយ (អាចជាការឃុបឃិតគ្នាក្នុងចំណោមអ្នកដេញថ្លៃ)។ |
| | • តើមានតម្លៃឯកតាដូចគ្នាទាំងស្រុងនៅក្នុងតម្លៃដេញថ្លៃ នៅពេលប្រៀបធៀបជាមួយតម្លៃឯកតានៅក្នុងការប៉ាន់ប្រមាណថ្លៃចំណាយរបស់ទីភ្នាក់ងារប្រតិបត្តិ ដែរឬទេ? | | | | សូមបញ្ជាក់អំពីអ្នកដេញថ្លៃដែលមានតម្លៃឯកតាដូចគ្នាទាំងស្រុង ទៅនឹងការប៉ាន់ប្រមាណថ្លៃចំណាយរបស់ទីភ្នាក់ងារប្រតិបត្តិ (អាចជាការឃុបឃិតគ្នារវាងអ្នកដេញថ្លៃ និងបុគ្គលិកទីភ្នាក់ងារប្រតិបត្តិ)។ |
| 19 | តើតម្លៃដេញថ្លៃមានកម្រិតទាបជាងតម្លៃប៉ាន់ប្រមាណ ដែរឬទេ? | | | | សូមបញ្ជាក់អំពីអ្នកដេញថ្លៃដែលមានតម្លៃទាបជាងតម្លៃប៉ាន់ប្រមាណ និងតម្លៃដេញថ្លៃរបស់ពួកគេ។ |
| 20 | សម្រាប់ទំនិញ ផ្អែកលើឯកសារចម្លងនៃតារាងស្តីពី “លក្ខណៈពិសេសនៃឯកសារដេញថ្លៃចំពោះលក្ខខណ្ឌតម្រូវបច្ចេកទេស” និងការដាក់ជូនឯកសារដេញថ្លៃ តើវិសាលភាពនៃការផ្គត់ផ្គង់ ព័ត៌មានបច្ចេកទេស និងទិន្នន័យបច្ចេកទេសដែលអ្នកដេញថ្លៃបានដាក់ជូន ត្រូវបានពិនិត្យមើលលម្អិត និងធ្វើការប្រៀបធៀបទៅនឹងលក្ខខណ្ឌតម្រូវបច្ចេកទេសនៃឯកសារដេញថ្លៃស្តង់ដារ ដែរឬទេ? | | | | ប្រសិនបើមិនត្រូវបានធ្វើទេនោះ សូមបញ្ជាក់អំពីមូលហេតុ និងមូលដ្ឋានសម្រាប់ការវាយតម្លៃ។ |
| 21 | ផ្អែកលើការត្រួតពិនិត្យឡើងវិញរបស់ខ្ញុំទៅលើការគ្របដណ្តប់នៃរបាយការណ៍វាយតម្លៃឯកសារដេញថ្លៃ ធៀបនឹងលក្ខណៈវិនិច្ឆ័យវាយតម្លៃទៅលើលក្ខណៈសម្បត្តិនៅក្នុងឯកសារដេញថ្លៃ តើវាមានសង្គតភាពជាមួយគ្នា ដែរឬទេ? | | | | ប្រសិនបើពុំមានសង្គតភាពជាមួយគ្នាទេនោះ សូមបញ្ជាក់ថាតើលក្ខណៈវិនិច្ឆ័យផ្អែកលក្ខណៈសម្បត្តិណាខ្លះនៅក្នុងឯកសារដេញថ្លៃ ដែលមិនត្រូវបានគ្របដណ្តប់ដោយរបាយការណ៍វាយតម្លៃឯកសារដេញថ្លៃ និងលក្ខណៈវិនិច្ឆ័យណាខ្លះនៅក្នុងរបាយការណ៍វាយតម្លៃ ដែលពុំមានគ្របដណ្តប់នៅក្នុងឯកសារដេញថ្លៃ។ |
| | • ផ្អែកលើឯកសារដែលអ្នកដេញថ្លៃបានដាក់ជូនសម្រាប់លក្ខណៈវិនិច្ឆ័យនីមួយៗ ដែលត្រូវវាយតម្លៃ និងការប៉ាន់ប្រមាណរបស់គណៈកម្មាធិការវាយតម្លៃឯកសារ | | | | |

| | | | | | |
|---|---|---|---|---|---|
| | ដេញថ្លៃ យោងតាមរបាយការណ៍វាយតម្លៃឯកសារដេញថ្លៃ ៖<br>○ តើលក្ខណៈវិនិច្ឆ័យទាក់ទងនឹងបទពិសោធន៍ ត្រូវបានវាយតម្លៃសមស្រប សម្រាប់អ្នកដេញថ្លៃគ្រប់រូប ដែរឬទេ? ចំពោះសមត្ថភាពផ្នែកហិរញ្ញវត្ថុ បណ្តឹងវិវាទដែលកំពុងរង់ចាំដោះស្រាយ។ល។ តើលក្ខណៈវិនិច្ឆ័យនីមួយៗ ត្រូវបានវាយតម្លៃសមស្រប ដែរឬទេ? | | | | ប្រសិនបើមិនត្រូវបានវាយតម្លៃសមស្រប ទេនោះ សូមបញ្ជាក់អំពីកង្វះខាតនៅក្នុងការវាយតម្លៃ។ |
| | ○ តើលក្ខណៈវិនិច្ឆ័យទាក់ទងទៅនឹងចំណូល និងចំណេញប្រចាំឆ្នាំជាមធ្យម និងសមត្ថភាពផ្នែកហិរញ្ញវត្ថុ ត្រូវបានវាយតម្លៃសមស្រប និងផ្ទៀងផ្ទាត់ធៀបទៅនឹងរបាយការណ៍សវនកម្មហិរញ្ញវត្ថុដែលបានដាក់ជូន ដែរឬទេ? | | | | ប្រសិនបើមិនត្រូវបានវាយតម្លៃសមស្រប ទេនោះ សូមបញ្ជាក់អំពីកង្វះខាតនៅក្នុងការវាយតម្លៃ។ |
| | ○ តើធនធានហិរញ្ញវត្ថុត្រូវបានផ្ទៀងផ្ទាត់ ដើម្បីពិនិត្យមើលទៅលើធម្មានុរូប/ភាពពិតប្រាកដ (ឧ. ខ្ទង់ឥណទាន។ល។) ដែរឬទេ? | | | | |
| | ○ តើលក្ខណៈវិនិច្ឆ័យអំពីបណ្តឹងវិវាទរង់ចាំដោះស្រាយ ត្រូវបានវាយតម្លៃ និងផ្ទៀងផ្ទាត់ ជាមួយនឹងកំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ ដែរឬទេ ប្រសិនបើមាន? | | | | ប្រសិនបើពុំមានការវាយតម្លៃ និងផ្ទៀងផ្ទាត់សមស្របទេនោះ សូមបញ្ជាក់អំពីកង្វះខាត។ |
| | • ប្រសិនបើលក្ខណៈវិនិច្ឆ័យផ្នែកលក្ខណៈសម្បត្តិត្រូវបានវាយតម្លៃសមស្របទេនោះ តើអ្នកដេញថ្លៃដែលត្រូវបានប្រកាសថាទទួលបានជ័យជំនះ គួរបានទទួលកិច្ចសន្យាដែរឬទេ? | | | | ប្រសិនបើមិនគួរទេនោះ សូមបញ្ជាក់ថាតើអ្នកដេញថ្លៃណាមួយដែលគួរទទួលបានកិច្ចសន្យា និងសូមបញ្ជាក់អំពីមូលហេតុ។ |

| | | | | | |
|---|---|---|---|---|---|
| 22 | តើមានឯកសារគាំទ្រគ្រប់គ្រាន់សម្រាប់ត្រួតពិនិត្យនីតិវិធីវាយតម្លៃ ដែរឬទេ? | | | | សូមបញ្ជាក់ថាតើឯកសារណាខ្លះដែលគ្មាន។ |
| | • តើខ្ញុំបានប្រើប្រាស់ឯកសារដេញថ្លៃច្បាប់ដើម ដើម្បីត្រួតពិនិត្យឡើងវិញទៅលើដំណើរការវាយតម្លៃ ដែរឬទេ? | | | | |
| | • តើមានការកែតម្រូវ/ការផ្លាស់ប្តូរ/ការកែប្រែខុសប្រក្រតីនៅលើឯកសារដេញថ្លៃក្រោយពេលដែលឯកសារទាំងនោះត្រូវបានបើក ដែរឬទេ? | | | | |
| 23 | នៅក្នុងដំណើរការវាយតម្លៃ តើទីភ្នាក់ងារប្រតិបត្តិ ឬ គណៈកម្មាធិការវាយតម្លៃការដេញថ្លៃ បានឆ្លើយតបទៅនឹងអ្នកដេញថ្លៃដែលធ្វើការសួរបញ្ជាក់ ដែរឬទេ? | | | | |
| | • ប្រសិនបើបានឆ្លើយតប តើមានការរក្សាទុកកំណត់ហេតុ នៃរាល់ការផ្តល់សេចក្តីបញ្ជាក់ដែលគេបានសួរនិងបានទទួល ដែរឬទេ? | | | | សូមបញ្ជាក់អំពីសេចក្តីលម្អិតនៃកំណត់ហេតុដែលគេមិនបានរក្សាទុក។ |
| 24 | តើកំណត់ហេតុនៃកិច្ចប្រជុំវាយតម្លៃ ត្រូវបានចុះហត្ថលេខាដោយសមាជិកគណៈកម្មាធិការវាយតម្លៃគ្រប់រូប ដែរឬទេ? | | | | សូមបញ្ជាក់អំពីសមាជិកដែលមិនបានចុះហត្ថលេខា។ |
| | • តើរបាយការណ៍វាយតម្លៃឯកសារដេញថ្លៃត្រូវបានចុះហត្ថលេខាដោយសមាជិកគណៈកម្មាធិការវាយតម្លៃឯកសារដេញថ្លៃគ្រប់រូប ដែរឬទេ? | | | | សូមបញ្ជាក់អំពីសមាជិកដែលមិនបានចុះហត្ថលេខា។ |
| | • តើរបាយការណ៍វាយតម្លៃការដេញថ្លៃរួមមានព័ត៌មានគ្រប់ជ្រុងជ្រោយ ដើម្បីផ្តល់ហេតុផលសម្រាប់ឆ្លើយតបចំពោះករណីអ្នកដេញថ្លៃដែលសន្មតថាពុំមានភាពសមស្រប (ផ្អែកលើការត្រួតពិនិត្យរបស់ខ្ញុំ) ត្រូវបានចាត់ទុកថាមានភាពសមស្រប ដែរឬទេ? | | | | |
| 25 | ក្នុងករណីមានការដេញថ្លៃឡើងវិញ តើការផ្តល់ហេតុផលសម្រាប់ទង្វើបែបនេះមានភាពសមស្រប ដែរឬទេ? | | | | សូមបញ្ជាក់អំពីហេតុផលក្នុងការដេញថ្លៃឡើងវិញ។ |

| | | | | | |
|---|---|---|---|---|---|
| | • តើមានបានទទួលការអនុម័តពីធនាគារអភិវឌ្ឍន៍អាស៊ី មុនពេលដេញថ្លៃឡើងវិញដែរឬទេ? | | | | ប្រសិនបើពុំមានការអនុម័តជាមុនពីធនាគារអភិវឌ្ឍន៍អាស៊ីទេនោះ សូមបញ្ជាក់អំពីហេតុផលដែលមិនបានសុំការអនុម័តពីធនាគារអភិវឌ្ឍន៍អាស៊ី។ |
| **ច.** | **ការផ្តល់ជូន និងការអនុវត្តន៍កិច្ចសន្យា** | | | | |
| 26 | តើកិច្ចសន្យាត្រូវបានផ្តល់ជូនក្រោយពេលទទួលបានការមិនជំទាស់ពីធនាគារអភិវឌ្ឍន៍អាស៊ី ដែរឬទេ? | | | | សូមបញ្ជាក់អំពីកាលបរិច្ឆេទដែលធនាគារអភិវឌ្ឍន៍អាស៊ីផ្តល់ការមិនជំទាស់ និងកាលបរិច្ឆេទផ្តល់កិច្ចសន្យា។ |
| 27 | តើមានការផ្តល់លិខិតធានាការអនុវត្តន៍គ្រប់គ្រាន់ មុនពេលផ្តល់ជូនកិច្ចសន្យាដែរឬទេ? | | | | |
| | • តើលិខិតធានាការអនុវត្តន៍នោះ ត្រូវបានពិនិត្យផ្ទៀងផ្ទាត់ ដើម្បីបញ្ជាក់អំពីភាពពិតប្រាកដរបស់វា ដែរឬទេ? | | | | |
| 28 | តើអ្នកដេញថ្លៃដែលបានទទួលជោគជ័យបានផ្តល់តម្លៃក្នុងកម្រិតទាបគួរឱ្យកត់សម្គាល់បើធៀបទៅនឹងការប៉ាន់ប្រមាណថ្លៃចំណាយដែរឬទេ? | | | | សូមបញ្ជាក់អំពីតម្លៃកិច្ចសន្យា ធៀបទៅនឹងការប៉ាន់ប្រមាណថ្លៃចំណាយ។ |
| | • ក្នុងករណីដែលតម្លៃមានកម្រិតទាបគួរឱ្យកត់សម្គាល់ តើមានការដាក់ជូននូវការកែប្រែកិច្ចសន្យា/ផ្លាស់ប្តូរលំដាប់លំដោយកិច្ចសន្យា ដែរឬទេ? | | | | សូមបញ្ជាក់ ប្រសិនបើការផ្លាស់ប្តូរលំដាប់លំដោយ បានធ្វើឱ្យបរិមាណ និងតម្លៃមានការកើនឡើង និង បញ្ជាក់អំពីហេតុផលនៃការធ្វើបែបនេះ។ |